00702229

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 06 / 2011
ម៉ោង (Time/Heure) : 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

E93

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២     កាលបរិច្ឆេទ: ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ

អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ថាបញ្ជីឈ្មោះបុគ្គលដែលអាចជាសាក្សី និងអ្នកជំនាញដែលភាគីបានដាក់អនុលោមតាមវិធានផ្ទៃក្នុង នឹងត្រូវលើកយកទៅពិភាក្សានៅក្នុងពេលសវនាការបឋម (ឯកសារលេខ E86)។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះក៏បានជូនដំណឹងដល់ភាគីអំពីចេតនារបស់ ខ្លួនក្នុងការចាប់ផ្តើមកិច្ចសវនាការលើអង្គសេចក្តី ដោយធ្វើការពិនិត្យពិចារណាលើចំណុចចំនួន៤ ដែលមានជាអាទិ៍ (១) រចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ (២) តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងអំឡុងពេលមុនការបង្កើតកម្ពុជាប្រជាធិបតេយ្យ រួមទាំងនៅពេលដែលជនជាប់ចោទបានទទួលតួនាទីនោះ (៣) តួនាទីរបស់ជនជាប់ចោទម្នាក់ៗនៅក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ជនជាប់ចោទតាមការចាត់តាំង វិសាលភាពនៃសិទ្ធិអំណាចរបស់ជនជាប់ចោទ និងខ្សែបណ្តាញទំនាក់ទំនងក្នុងអំឡុងរយៈកាលក្រោមយុត្តាធិការរបស់ អ.វ.ត.ក និង (៤) គោលនយោបាយនៃ

E93

កម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហានានា ដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ៤៥)។

នៅក្នុងសវនាការបឋម អង្គជំនុំជម្រះនឹងកំរិតការពិភាក្សាអំពីសាក្សី និងអ្នកជំនាញដែលភាគីបានស្នើសុំកោះហៅ មកនៅត្រឹមជាការពិភាក្សាអំពីសាក្សី និងអ្នកជំនាញទាំងឡាយណាដែលពាក់ព័ន្ធនឹងចំណុចទាំង ៤ ខាងលើប៉ុណ្ណោះ។ ដើម្បីសម្រួលដល់ការត្រៀមរៀបចំសម្រាប់សវនាការនេះ អង្គជំនុំជម្រះសូមជូនព័ត៌មានបន្ថែមឱ្យភាគីបានជ្រាបដូចខាងក្រោម៖

- អង្គជំនុំជម្រះបានវិភាគលើបញ្ជីឈ្មោះសាក្សីដែលភាគីបានដាក់។ ដោយហេតុថាជនជាប់ចោទមានសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស និងយុត្តិធម៌ វាមានភាពចាំបាច់ក្នុងការកាត់បន្ថយឱ្យបានច្រើននូវចំនួនសាក្សីដែលត្រូវកោះហៅ។ ជាងនេះទៅទៀត មួយផ្នែកធំនៃបញ្ជីទាំងនេះមានឈ្មោះសាក្សី និងអ្នកជំនាញថ្មីដែលភាគីបានស្នើសុំកោះហៅ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសូមស្នើឱ្យភាគីបំពេញកិច្ចមួយចំនួនដូចខាងក្រោមឱ្យបានរួចរាល់មុនពេលសវនាការបឋម៖

*i.* *ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) ធ្លាប់បានស្តាប់ចម្លើយ៖*

សូមភាគីបញ្ជាក់តាមលំដាប់លំដោយនៃភាពពាក់ព័ន្ធ និងតម្លៃជាភស្តុតាងនូវឈ្មោះសាក្សី និងអ្នកជំនាញដែលខ្លួនចាត់ទុកថាពាក់ព័ន្ធជាងគេទៅនឹងចំណុចទាំង ៤ ខាងលើ។

*ii.* *ពាក់ព័ន្ធនឹងសាក្សីថ្មី និងអ្នកជំនាញថ្មីដែលភាគីស្នើសុំកោះហៅ៖* សូមភាគីបញ្ជាក់តាមលំដាប់លំដោយនៃភាពពាក់ព័ន្ធ និងតម្លៃជាភស្តុតាង នូវឈ្មោះសាក្សីថ្មី និងអ្នកជំនាញថ្មីដែលខ្លួនចាត់ទុកថាពាក់ព័ន្ធជាងគេទៅនឹងចំណុចទាំង៤ ខាងលើ ព្រមទាំងមូលហេតុរបស់ខ្លួន (ឧទាហរណ៍ដូចជា ពួកគេបានដឹងដោយផ្ទាល់ និងច្បាស់លាស់អំពីការចោទប្រកាន់នានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមានតម្លៃជាភស្តុតាងរឹងមាំជាងសាក្សីផ្សេងៗដែលខ្លួនបានស្នើសុំកោះហៅ។ល។) ភាគីក៏គួរបញ្ជាក់អំពីមូលហេតុដែលកន្លងមកខ្លួនពុំបានស្នើសុំឱ្យ ក.ស.ច.ស ស្តាប់យកចម្លើយសាក្សី និងអ្នកជំនាញថ្មីទាំងអស់នេះ (ឬក្នុងករណីដែល ក.ស.ច.ស បាន

បដិសេធពុំស្ដាប់ចម្លើយពួកគេ សូមភាគីបញ្ជាក់អំពីមូលហេតុនៃការបដិសេធពុំព្រមស្ដាប់ចម្លើយរបស់ ក.ស.ច.ស ប្រសិនបើខ្លួនបានដឹង)។

- សម្រាប់បញ្ជីឈ្មោះ និងសេចក្ដីពន្យល់បន្ថែមដែលអង្គជំនុំជម្រះបានស្នើសុំនេះ ភាគីគួរសង្ខេបឱ្យបានខ្លីតាមដែលអាចធ្វើទៅបាន និងដាក់ជូនអង្គជំនុំជម្រះត្រឹមថ្ងៃ ច័ន្ទ ទី ២០ ខែ មិថុនា ឆ្នាំ២០១១។ ដោយហេតុថាអង្គជំនុំជម្រះនឹងយកឯកសារទាំងនេះទៅប្រើប្រាស់ជាឯកសារផ្ទៃក្នុងសម្រាប់តែអង្គជំនុំជម្រះដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសាក្សី និងមូលដ្ឋានទិន្នន័យដែលមានស្រាប់នោះ ក្នុងករណីពិសេស ភាគីអាចដាក់ឯកសារទាំងនេះជូនអង្គជំនុំជម្រះត្រឹមតែជាភាសាខ្មែរ ភាសាអង់គ្លេស ឬភាសាបារាំង ក៏បាន។ ប្រសិនបើភាគីចង់ឆ្លើយតបទៅនឹងឯកសារទាំងនេះ ភាគីអាចធ្វើដោយផ្ទាល់មាត់នៅក្នុងពេលសវនាការបឋម។

បន្ទាប់ពីសវនាការបឋម និងក្រោយការស្ដាប់សេចក្ដីសន្និដ្ឋានរបស់ភាគី អង្គជំនុំជម្រះនឹងប្រកាសបញ្ជីឈ្មោះសាក្សីបឋមសម្រាប់ដំណាក់កាលដំបូងនៃការជំនុំជម្រះ។ (សាក្សីពាក់ព័ន្ធផ្សេងៗអាចត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះសាក្សីបម្រុង សម្រាប់ឱ្យអង្គជំនុំជម្រះកោះហៅក្នុងករណីសាក្សីដែលមានឈ្មោះនៅក្នុងបញ្ជីបឋមពុំអាចចូលខ្លួនមកផ្ដល់សក្ខីកម្មបាន)។ ដោយហេតុថានៅពេលបន្ទាប់អង្គជំនុំជម្រះនឹងស្នើសុំឱ្យភាគីបញ្ជាក់អំពីឯកសារនានា ដែលខ្លួនចាត់ទុកថាពាក់ព័ន្ធទៅនឹងចំណុចទាំង ៤ ខាងលើ អង្គជំនុំជម្រះក៏សូមស្នើឱ្យភាគីចាប់ផ្ដើមពិនិត្យឯកសាររបស់ខ្លួនពីពេលនេះតទៅឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

នៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះបដិសេធសំណើរបស់ក្រុមមេធាវីការពារក្ដី អៀង សារី និង នួន ជា (ឯកសារលេខ E89 និង E89/1) ដែលបានស្នើសុំដាក់បញ្ចូលទៅក្នុងបញ្ជីនៃបញ្ហាដែលអង្គជំនុំជម្រះនឹងត្រូវស្ដាប់នៅក្នុងសវនាការ នូវប្រធានបទមួយចំនួនពាក់ព័ន្ធនឹងសម័យមុនឆ្នាំ ១៩៧៥ និងសម័យក្រោយឆ្នាំ ១៩៧៩ បន្ថែមពីលើចំណុចពាក់ព័ន្ធផ្សេងៗទៀតដែលអង្គជំនុំជម្រះបានកំណត់ថា នឹងធ្វើការដេញដោល។ អង្គជំនុំជម្រះនឹងលើកយកបញ្ហា និងហេតុការណ៍នានាដែលពុំស្ថិតក្រោមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក មកពិនិត្យពិចារណា លុះត្រាណាតែហេតុការណ៍ និងបញ្ហាទាំងអស់នោះជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងបញ្ហាក្រោមយុត្តាធិការរបស់ អ.វ.ត.ក និងវិសាលភាពនៃការជំនុំជម្រះ ប៉ុណ្ណោះ។